EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៦៤៩ សហ.១៤ អអក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ សៅ សូរិយា

<u>យោង</u>៖ កំណត់ហេតុប្រជុំនៅសាលាឃុំរមណីយ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤។

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនសាធារណជន**អ្នកប្រើប្រាស់អគ្គិសនីក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី** របស់សេវាករឈ្មោះ សៅ សូរិយា នៅឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ មេត្តាជ្រាបថា លើមូលដ្ឋាននៃយុទ្ធសាស្ត្រពង្រីកអគ្គិសនីចេញពីអនុស្ថានីយ ដែលមានថ្លៃសមរម្យ កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាបានសម្រេចអនុញ្ញាតឲ្យ **ក្រុមហ៊ុន ប៊ី វី ស៊ី ផៅវ័រ ឌីវែឡុបមិន** ធ្វើការវិនិយោគសាងសង់ខ្សែពង្រីកបណ្តាញបញ្ជូនវង ចេញពីខេត្តកំពង់ធំ ដើម្បីបញ្ជូនអគ្គិសនីចេញពីអនុស្ថានីយក្រុងកំពង់ចាម ទៅផ្គត់ផ្គង់ឲ្យតំបន់ចែកចាយមួយចំនួនទៀត ក្នុងខេត្តព្រះវិហារ ដើម្បីបន្ធូរបន្ថយអត្រាថ្លៃលក់បច្ចុប្បន្នឲ្យថយចុះបន្តិចម្តងៗ សម្រួលដល់ប្រជាពលរដ្ឋអ្នកប្រើប្រាស់។ បន្ទាប់ពីបានធ្វើការពិនិត្យ វិភាគថ្លៃដើមអគ្គិសនីបច្ចុប្បន្នរបស់ក្រុមហ៊ុនបញ្ជូនវង និងរបស់សេវាករ សៅ សូរិយា និងយោងតាមស្មារតីសម្រេចនៃអង្គប្រជុំពិភាក្សា នៅសាលារមណីយ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបញ្ចុះថ្លៃអគ្គិសនីនៅតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ សៅ សូរិយា **ចុះពីអត្រាថ្លៃលក់ ២,៩០០ រៀល/គីឡូវ៉ាត់ម៉ោង មក ១,៦០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្តគិតពីពេលតភ្ជាប់យកប្រភពថាមពលប្រើប្រាស់ពីក្រុមហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវែឡុបមិន នៅខែធ្នូ ឆ្នាំ២០១៤ និងបញ្ចុះមក ១,៥០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្តថាមពលប្រើប្រាស់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៥។**

នៅឆ្នាំ២០១៦ អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិនិត្យ និងកំណត់អត្រាថ្លៃលក់អគ្គិសនីឡើងវិញ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ សៅ សុរិយា មេត្តាជ្រាបជាពត៌មាន ដោយអនុគ្រោះ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

<u>ចម្លងជូន</u>
- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តព្រះវិហារ
- មន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ
- សាលាស្រុករវៀង
- សាលាឃុំរមណីយ

  "ដើម្បីជូនជ្រាប"
- ក្រុមហ៊ុន ប៊ី វី ស៊ី ផៅវ័រ ឌីវែឡុបមិន
- សេវាករ សៅ សូរិយា

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ